# រឿង កូនកណ្តុរនិងជីស



ឆ្នាំ ២០១០


អ្នកនិពន្ធ : លោកស្រី តឹក ស៊ីផុន

អ្នករៀបរៀង : លោកស្រី ឈុំ សារ៉ានី

វិចិត្រករ : លោក អ៊ុត រឿន



បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពីក្រសួងអប់រំ សេចក្តីសម្រេចលេខ ១៣៨ អរ.សសរ.

ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩០ ដើម្បីប្រើប្រាស់នៅតាមសាលារៀនមត្តេយ្យ

**គ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ**

បោះពុម្ពលើកទី១ ចំនួន៥,០០០ក្បាល

រោងពុម្ពក្រសួងអប់រំ ឆ្នាំ១៩៩១

អំណោយ អ៊ុយនីសេហ្វ

DON DE L'UNICEF

បោះពុម្ពលើកទី២ដោយ : អង្គការគាំពារកុមារខ្មែរ (CYK)

ភ្នំពេញ ខែកក្កដា ឆ្នាំ២០១០

មូលនិធិ : ប្រាក់សន្សំរបស់អ្នកចូលរួមទាំងអស់នៅប្រៃសណីយ៍ជប៉ុនសម្រាប់ជំនួយស្ម័គ្រចិត្តអន្តរជាតិ

ចំនួន : ៥,០០០ក្បាល

លេខ : CYK N10015

រោងពុម្ព : **J S R C** Printing House

រាល់យប់មុនពេលចូលដំណេក កុមារីសូភីតែងបានទុកដីសនិងក្ដារឆ្នួននៅលើតុមួយនៅក្បែរគ្រែរបស់នាង។ នាងស្រឡាញ់ដីសនេះណាស់ ព្រោះវាចេះស្ដាប់បង្គាប់ និងអាចបំពេញចំណង់ចំណូលចិត្តនាងបាន។

យប់មួយសូភីបានគេងលង់លក់ស្កប់ស្កល់ ស្រាប់តែកូនកណ្ដុរមួយលោតឡើងលើតុ ហើយក្រឡេកឃើញដីសមួយដើម ក៏អួសនាំយកទៅសំបុក។





ដីសស្រែកអង្វរកណ្ដុរថា៖ "លែងខ្ញុំទៅ លែងខ្ញុំទៅ លោកយកខ្ញុំធ្វើអ្វី បើខ្ញុំជាដីស? តើដីសអាចធ្វើជាចំណីលោកបានដែរឬទេ?"

កូនកណ្ដុរតបវិញថា៖ "ខ្ញុំនឹងកកេរឯងត្បិតខ្ញុំរមាស់ធ្មេញណាស់ ហើយយើងត្រូវតែអង្កៀមឯងទាល់តែអស់"។ និយាយហើយ កូនកណ្ដុរក៏ខាំដីសភ្លាម។

ដីសស្រែកថ្ងូរ៖ "អូយ អូយ សូមលោកមេត្តាទុកឱ្យខ្ញុំគូរបានម្ដង ជាលើកចុងក្រោយនៃជីវិតខ្ញុំ រួចហើយលោកធ្វើអ្វីខ្ញុំក៏ធ្វើតាមអំពើចិត្តលោកចុះ"។





កូនកណ្ដុរយល់ព្រមដោយពោលថា៖ “ល្អ ឯងគូរទៅចុះ ប៉ុន្តែគូររួចពេលណា យើងនឹងកកេរខាំទំពារឯងជាដុំតូចៗ”។

ដីសដកដង្ហើមធំ ហើយគូររង្វង់មូលមួយ និងដាក់រន្ធមូលកណ្ដាល។ កូនកណ្ដុរសួរថា៖ “ពិតជាសាច់គោអាំងមួយដុំឬ រីឯរង្វង់តូចនោះ គឺរន្ធដែលគេដោតមែនទេ?”

ដីសឆ្លើយថា៖ “ប្រហែលមែនហើយ” ក៏បន្តគូររង្វង់មូលមួយទៀតធំជាងមុន។





កូនកណ្ដុរលាន់មាត់ថា៖ “នោះគឺចំណិតនំប៉័ងមែនទេ? ឱត្រូវហើយ សាច់គោអាំងជាមួយនំប៉័ង”។

ដីសឆ្លើយថា៖ “ប្រហែលមែនហើយ” ក៏បន្តគូរង្វង់មូលទ្រវែងផ្សេងទៀត។







ដឹសបានគូរបន្ថែមខ្លួនប្រាណ និងពុកមាត់ស្រមេមស្រមាម...

"ឆ្មាមែន ឆ្មាមែន" កូនកណ្ដុរស្រែកផងយំផងដោយភ័យញ័ររន្ធត់ ហើយស្រែកបន្តទៀតថា៖ "ជួយផង១" រួចរត់ទៅជ្រកសំងំក្នុងរូងបាត់ទៅ។



ក្រសួងអប់រំ យុវជន និងកីឡា
នាយកដ្ឋានអប់រំកុមារតូច

This aid project is supported by all participants in Japan's
Postal Saving for International Voluntary Aid.
និងអង្គការគាំពារកុមារខ្មែរ ( CYK )

9789996317118